ស្ថានទូតសហរដ្ឋអាមេរិក
#១ ផ្លូវ៩៦ សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

សេចក្តីណែនាំចំពោះបេក្ខជនសុំទិដ្ឋាការមិនមែនអន្តោប្រវេសន៍ប្រភេទគូដណ្តឹង

ការិយាល័យកុងស៊ុលយើងខ្ញុំបានទទួលសំណុំរឿងដែលធានាលោកអ្នកឲ្យក្លាយជាបេក្ខជនមានសិទ្ធិសុំទិដ្ឋាការមិនមែនអន្តោប្រវេសន៍ប្រភេទគូដណ្តឹងទៅសហរដ្ឋអាមេរិកដើម្បីរៀបការជាមួយអ្នកធានា។ ដើម្បីត្រៀមខ្លួនសម្រាប់ការសម្ភាសន៍ជាមួយមន្ត្រីកុងស៊ុល សូមលោកអ្នកអានសេចក្តីណែនាំនេះដោយយកចិត្តទុកដាក់និងធ្វើតាមការណែនាំដូចខាងក្រោមនេះ។

ជំហានដំបូង៖ សូមបំពេញពាក្យសុំ DS-160 សម្រាប់បេក្ខជននីមួយៗដែលមានបំណងធ្វើដំណើរទៅសហរដ្ឋអាមេរិក។ ដើម្បីបំពេញពាក្យសុំ DS-160 សូមចូលទៅកាន់គេហទំព័រ https://ceac.state.gov/genniv/។

សូមណាត់ពេលវេលានិងថ្ងៃសម្ភាសន៍ដោយធ្វើតាមសេចក្តីណែនាំនៅលើគេហទំព័រនេះ https://www.ustraveldocs.com/kh_cy/kh-iv-kvisa.asp។

ជំហានទីពីរ៖ លោកអ្នកត្រូវមានឯកសារដែលមានក្នុងបញ្ជីខាងក្រោមនេះរួចជាស្រេចមុនថ្ងៃមកសម្ភាសន៍។ លោកអ្នក**មិនត្រូវផ្ញើ**ឯកសារទាំងនេះមកការិយាល័យកុងស៊ុលទេ ប៉ុន្តែត្រូវកាន់មកនៅថ្ងៃសម្ភាសន៍។

១- លិខិតឆ្លងដែន៖ លិខិតឆ្លងដែនដែលមានសុពលភាពប្រើប្រាស់ក្នុងការធ្វើដំណើរទៅសហរដ្ឋអាមេរិក ហើយដែលមានសុពលភាពយ៉ាងតិច ៦ ខែ។ កូនៗរបស់លោកអ្នកគឺត្រូវតែមានលិខិតឆ្លងដែនដោយឡែករៀងៗខ្លួន ទោះបីជាអាយុប៉ុន្មានក៏ដោយ។

២- សំបុត្រកំណើត៖ លោកអ្នកត្រូវបង្ហាញសំបុត្រកំណើតច្បាប់ដើម និងច្បាប់ចម្លងមួយច្បាប់។

៣-រូបថត៖ រូបថត២សន្លឹក (ទំហំ ២ x ២ អ៊ិញ ឬ ៥ x ៥ ស.ម) ថតចំពីមុខ ផ្ទៃក្រោយពណ៌ស។ សូមទៅកាន់គេហទំព័រ https://kh.usembassy.gov/km/visas-km/immigrant-visas-km/medical-examination-instructions-km/ ដើម្បីអានសេចក្តីណែនាំអំពីការថតរូប។

៤- សាលក្រមលែងលះឬលិខិតមរណភាព៖ បេក្ខជនទាំងអស់ដែលធ្លាប់រៀបការត្រូវតែមានភ័ស្តុតាងនៃការបញ្ចប់អាពាហ៍ពិពាហ៍មុនៗដូចជា សំបុត្របញ្ជាក់មរណភាព ឬសាលក្រមលែងលះ និងលិខិតបញ្ជាក់ស្តាពរ។

Last updated: 30-Dec-2020

៥- ភ័ស្តុតាងនៃទំនាក់ទំនង៖ អ្នកគួរយកភស្តុតាងដែលបង្ហាញពីទំនាក់ទំនងរវាងអ្នកនិងអ្នកធានា។ ឧទាហរណ៍នៃភស្តុតាងទាំងនោះអាចជា (តែមិនកំណត់ត្រឹម) សំបុត្រឆ្លើយឆ្លង រូបថត និងភ័ស្តុតាងផ្សេងៗ ដែលលោកអ្នកគិតថាជាភ័ស្តុតាងនៃទំនាក់ទំនងរវាងលោកអ្នកជាមួយអ្នកធានា។

៦- ពិនិត្យសុខភាព៖ រាល់បេក្ខជនសុំទិដ្ឋាការប្រភេទគ្រួដណ្តឹងទាំងអស់ទោះបីជាអាយុប៉ុន្មានក៏ដោយ ត្រូវតែពិនិត្យសុខភាពអោយបានរួចរាល់។ ដើម្បីអានសេចក្តីណែនាំអំពីការពិនិត្យសុខភាពសម្រាប់បេក្ខជនសូមទៅកាន់គេហទំព័រ https://kh.usembassy.gov/km/visas-km/immigrant-visas-km/medical-examination-instructions-km/។

៨- ព្រឹត្តិប័ត្រថ្កោលទោស៖ រាល់បេក្ខជនសុំទិដ្ឋាការដែលមានអាយុចាប់ពី១៦ឆ្នាំឡើងទៅ ត្រូវតែមានព្រឹត្តិប័ត្រថ្កោលទោសដែលចេញដោយអាជ្ញាធរនៃប្រទេសដែលខ្លួនកំពុងស្នាក់នៅ ប្រសិនបើបានស្នាក់នៅក្នុងប្រទេសនេះលើសពី ៦ខែ។ បេក្ខជនត្រូវតែមានព្រឹត្តិប័ត្រថ្កោលទោសដែលចេញដោយអាជ្ញាធរនៃប្រទេសកំណើតរបស់ខ្លួនផងដែរ ប្រសិនបើខុសពីប្រទេសដែលខ្លួនកំពុងស្នាក់នៅ ហើយបើស្នាក់នៅក្នុងប្រទេសកំណើតរបស់ខ្លួននោះលើសពី៦ខែចាប់តាំងពីខ្លួនមានអាយុ១៦ឆ្នាំ។ បេក្ខជនទាំងអស់ក៏តម្រូវអោយមានព្រឹត្តិប័ត្រថ្កោលទោស ប្រសិនបើលោកអ្នកធ្លាប់ស្នាក់នៅប្រទេសក្រៅលើសពី១ឆ្នាំចាប់តាំងពីខ្លួនមានអាយុ១៦ឆ្នាំឡើង។ ព្រឹត្តិប័ត្រថ្កោលទោសក៏ត្រូវតែមានផងដែរចំពោះបេក្ខជនដែលធ្លាប់ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរមានសម្តត្តកិច្ច ទោះក្នុងករណីអ្វីក៏ដោយ ហើយក៏មិនគិតពីរយៈពេលនៃការស្នាក់នៅក្នុងប្រទេសនោះឡើយ។ ព្រឹត្តិប័ត្រថ្កោលទោសនោះត្រូវតែគ្របដណ្តប់រយៈពេលនៃការស្នាក់នៅទាំងស្រុងរបស់បុគ្គលនោះក្នុងប្រទេសណាដែលគេស្នាក់នៅ។ ព្រឹត្តិប័ត្រថ្កោលទោសដែលចេញដោយអាជ្ញាធរនៃប្រទេសដែលលោកអ្នកកំពុងរស់នៅត្រូវតែជាព្រឹត្តិប័ត្រដែលទើបចេញថ្មីៗ។ ព្រឹត្តិប័ត្រថ្កោលទោស គឺជាលិខិតចេញដោយអាជ្ញាធរដែលបង្ហាញពី របាយការណ៍ពាក់ព័ន្ធនឹងបេក្ខជននីមួយៗរួមមានរាល់បទល្មើស និងមូលហេតុនៃការចាប់ខ្លួន ព្រមទាំងការដោះលែងផងដែរ។ នៅ**ប្រទេសកម្ពុជា** ព្រឹត្តិប័ត្រថ្កោលទោសត្រូវចេញដោយក្រសួងយុត្តិធម៌ ដែលមានអាសយដ្ឋាន៖ #២៤០ ផ្លូវសម្តេចសុធារស រាជធានីភ្នំពេញ (ទល់មុខព្រះបរមរាជវាំង)។ សម្រាប់ប្រទេសផ្សេងទៀត សូមចូលមើលគេហទំព័រ http://travel.state.gov/content/visas/en/fees/reciprocity-by-country.html។

៨- លិខិតបញ្ជាក់ការងារកងទ័ព៖ លិខិតបញ្ជាក់នេះ គឺតម្រូវឲ្យបេក្ខជនស្នើសុំពីនាយកដ្ឋាន អង្គភាព ឬ ការិយាល័យដែលបេក្ខជនកំពុងឬធ្លាប់បម្រើការងារជាកងទ័ព។ លិខិតនេះគឺជាកំណត់ត្រា ពីប្រវត្តិការងារទាំងស្រុង ដែលបេក្ខជនធ្លាប់បំពេញការងារ។ លិខិតនេះក៏ត្រូវបញ្ជាក់ផងដែរ រាល់កំហុសការងារ ឬបទល្មើសដែល ត្រូវបានផ្តន្ទាទោសដោយតុលាការយោធា។

៩- កំណត់ត្រាតុលាការនិងពន្ធនាគា៖ បេក្ខជនដែលបានប្រព្រឹត្តបទល្មើសត្រូវតែមានលិខិត កំណត់ត្រាដែលបានបញ្ជាក់ពីរាល់តុលាការនិងពន្ធនាគារ ទោះបីជាទោសនោះត្រូវបានទទួលការលើកលែងក៏ដោយ។

១០- ពាក្យធានាផ្នែកហិរញ្ញវត្ថុ I-134 ច្បាប់ដើម និងឯកសារពន្ធ (Tax Transcripts) ចុងក្រោយរបស់អ្នកធានា។ លោកអ្នកអាចទាញយកពាក្យធានា **I-134** នេះបានតាមរយៈគេហទំព័រ http://www.uscis.gov/I-134។ ហើយសូមទៅកាន់គេហទំព័រ www.irs.gov សម្រាប់ព័ត៌មានអំពីរបៀបយកឯកសារពន្ធ (Tax Transcripts)។

១១- ការបកប្រែឯកសារ៖ រាល់ឯកសារដែលមិនមែនជាភាសារអង់គ្លេស ត្រូវតែមានភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសារអង់គ្លេស ដោយអ្នកបកប្រែអះអាងថាបានបកប្រែត្រឹមត្រូវនិងចប់សព្វគ្រប់ ហើយដោយមានឯកសារបញ្ជាក់ថាអ្នកបកប្រែនោះមានសមត្ថភាពអាចបកប្រែភាសាបរទេសទៅជាភាសាអង់គ្លេសបាន។

<u>ចំណាំ</u>៖ លោកអ្នកមិនត្រូវសាកសួរព័ត៌មានមកស្ថានទូតអំពីសំណុំរឿងរបស់លោកអ្នកឡើយ លើកលែងតែលោកអ្នកត្រូវជូនដំណឹងមកស្ថានទូតក្នុងករណីដែលស្ថានភាពរបស់លោកអ្នកមានការប្រែប្រួលដូចជា លោកអ្នករៀបអាពាហ៍ពិពាហ៍ ឬអ្នកធានាបានទទួលមរណភាពជាដើម។ សូមកុំផ្ញើឯកសារអ្វីមកស្ថានទូត ប្រសិនបើស្ថានទូតមិនតម្រូវឲ្យលោកអ្នកធ្វើដូច្នោះទេ។